# ព្រះរាជក្រឹត្យ

នស/រកត/១០០៥/៤២១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០៥/១៩៣ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើត ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០៥/២១១ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន
- បានទ្រង់យល់កិច្ចពិភាក្សារវាងគណបក្ស ហ៊្វុនស៊ិនប៉ិច គណបក្សប្រជាជនកម្ពុជា និងសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបាននិរាករណ៍ ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០៥/១៩៣ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន និងព្រះរាជក្រឹត្យ លេខ នស/រកត/០៥០៥/២១១ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៥១០.៤៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥

លេខ ...៩៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ១០ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សាជី តាន់**

Downloaded from http://www.khmerlaws.com